ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
# ស្ដីពី
# លទ្ធផលការងាររបស់ព្រឹទ្ធសភា
# ប្រចាំខែកញ្ញា ឆ្នាំ២០១៨

នៅក្នុងខែកញ្ញា ឆ្នាំ២០១៨នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ:

## ១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា

### ១.១ សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា បាន៖

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្ដីទីចំនួន០១លើក

-អញ្ជើញជាកិត្តិយសក្នុងពិធីបើកសម័យប្រជុំដំបូងនៃរដ្ឋសភា នីតិកាលទី៦ ក្រោមព្រះរាជអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតព្រះករុណា **ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា

-អញ្ជើញជូនព្រះរាជដំណើរព្រះករុណា **ព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្ដេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** យាងទៅកាន់ទីក្រុងប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

-អនុញ្ញាតឱ្យ ឯកឧត្តម Xiong Bo ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំនៅព្រះរាជាណាចក្រកម្ពុជាចូលជួបសម្ដែងការគួរសម និងជម្រាបលា

-អនុញ្ញាតឱ្យឯកឧត្តម Song Tao រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងអន្តរជាតិគណៈកម្មាធិការបក្សកុម្មុយនីស្តចិន ចូលជួបសម្ដែងការគួរសម

-អនុញ្ញាតឱ្យលោកជំទាវ **ស៊ុលម៉ា ស្វារ៉ាជ** (Sushma Swaraj) រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋឥណ្ឌា ចូលជួបសម្ដែងការគួរសម

-អនុញ្ញាតឱ្យគណៈប្រតិភូនាវាយុវជនអាស៊ីអាគ្នេយ៍កម្ពុជា និងជប៉ុន (SSEAYP) លើកទី៤៥ ឆ្នាំ២០១៨ ចូលជួបសម្ដែងការគួរសម

-អញ្ជើញជាកិត្តិយសក្នុងពិធីសច្ចាប្រណិធាន នៅក្នុងព្រះបរមរាជវាំង

-អញ្ជើញជួបសំណេះសំណាល និងសាកសួរសុខទុក្ខជាមួយប្រជាពលរដ្ឋនៅខេត្តកោះកុង ខេត្តប៉ៃលិន ខេត្តក្រចេះ ព្រមទាំងសួរសុខទុក្ខប្រជាពលរដ្ឋដែលកំពុងទទួលរងការប៉ះពាល់ដោយសារគ្រោះទឹកជំនន់ នៅភូមិកណ្តាលកោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម

-អញ្ជើញប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលជូនដល់ដួងវិញ្ញាណក្ខន្ធបុព្វការីជន និងញាតិកាទាំង៧សន្តានរបស់សម្តេច នៅភូមិកណ្តាលកោះ ស្រុកកោះសូទិន ខេត្តកំពង់ចាម

-អញ្ជើញគោរពវិញ្ញាណក្ខន្ធនិងចូលរួមរំលែកទុក្ខក្រុមគ្រួសារសពឯកឧត្តម **កើ ណៃលាង** ទីប្រឹក្សាក្រសួងអប់រំ យុវជន និងកីឡា នៅភូមិគ្រឹះលេខ៣០ ផ្លូវលេខ៤៥៦ សង្កាត់ទួលទំពូង២ ខណ្ឌចំការមន រាជធានីភ្នំពេញ

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៧០ ទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន៧០ច្បាប់ ទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៦៦ច្បាប់ ពីរដ្ឋសភាចំនួន០៣ច្បាប់ ធ្វើសំណើក្នុងនាមប្រមុខរដ្ឋស្តីទីចំនួន០១ច្បាប់

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៦ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៥ច្បាប់ ។

**១.២.ឯកឧត្តម នៃ ប៉េណា អនុប្រធានទី១ព្រឹទ្ធសភា បាន :**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញចូលរួមបើកសម័យប្រជុំដំបូងរបស់រដ្ឋសភានីតិកាលទី៦ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៧ច្បាប់ ។

**១.៣.ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា បាន :**

-អនុញ្ញាតឱ្យឯកឧត្តម LI Xiaoan អនុប្រធានគណៈកម្មាធិការសភាប្រឹក្សានយោបាយចិនប្រចាំខេត្តឡៅនីងនៃសាធារណរដ្ឋប្រជាមានិតចិន ចូលជួបសម្តែងការគួរសមក្នុងឱកាសដែលឯកឧត្តមអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា

-អញ្ជើញជួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយឯកឧត្តម Tan Chuan-Jin ប្រធានមហាសន្និបាតអន្តរសភា(AIPA) និងជាប្រធានសភាសាធារណរដ្ឋសិង្ហបុរី,

ឯកឧត្តម Do Ba Ty ប្រធានគណៈប្រតិភូសភាវៀតណាម និងលោកជំទាវ Mdm Halimah Yacob ប្រធានាធិបតីនៃសាធារណរដ្ឋសិង្ហបុរី ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈ-ប្រតិភូព្រឹទ្ធសភាកម្ពុជា ទៅចូលរួមកិច្ចប្រជុំមហាសន្និបាតអន្តរសភា(AIPA) លើកទី៣៩ នៅសាធារណរដ្ឋសិង្ហបុរី

-អញ្ជើញចូលរួមក្នុងជំនួបទ្វេភាគីជាមួយឯកឧត្តម Yin Li អភិបាលខេត្តស៊ីឈួន ប្រធានគណៈកម្មាធិការរៀបចំពិធីពិព័រណ៍អន្តរជាតិចិនភាគខាងលិចលើកទី១៧ (17th WCIF) និងជាលេខាធិការរងបក្សកុម្មុយនីស្តចិនខេត្តស៊ីឈួន ដោយបានពិភាក្សាលើការអនុវត្តគំនិតផ្តួចផ្តើមផ្លូវមួយខ្សែក្រវាត់មួយ និងការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-ស៊ីឈួននាពេលអនាគត ជាពិសេសការបង្កើនជើងហោះហើរត្រង់កម្ពុជាបន្ថែមពីខេត្តព្រះសីហនុទៅខេត្តស៊ីឈួន ដែលបច្ចុប្បន្នមានជើងហោះហើរត្រង់ពីខេត្តស៊ីឈួនមកខេត្តសៀមរាប និងការបង្កើនទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា និងខេត្តស៊ីឈួន

-អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ទៅចូលរួមជាកិត្តិយសក្នុងពិធីពិព័រណ៍អន្តរជាតិចិនភាគខាងលិចលើកទី១៧ នៅទីក្រុង Chengdu ខេត្ត Sichuan នៃសាធារណរដ្ឋប្រជាមានិតចិន

-អញ្ជើញចូលរួមក្នុងកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប(ASEP) លើកទី១០ និងបានជួបសំណេះសំណាល និងពិសាអាហារសាមគ្គីជាមួយបងប្អូនខ្មែររស់នៅប្រទេសប៊ែលហ្ស៊ិក និងហូឡង់

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការរៀបចំកម្មវិធីបុណ្យសព និងដឹកនាំគណៈ-ប្រតិភូព្រឹទ្ធសភា ទៅគោរពវិញ្ញាណក្ខន្ធ ព្រមទាំងចូលរួមក្នុងកម្មវិធីបុណ្យសពឯកឧត្តម **នៃ ប៉េណា** អនុប្រធានទី១ ព្រឹទ្ធសភា ដែលបានទទួលមរណភាពកាលពីថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៨ នៅគេហដ្ឋានសព

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៣ច្បាប់ ។

**២.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា** :

ក្នុងខែកញ្ញានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម:

**២.១. មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-អញ្ជើញជួបសវនាការការងារជាមួយក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ នៅទីស្តីការក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ

-អញ្ជើញចុះបំពេញបេសកកម្មដើម្បីឈ្វេងយល់ពីសភាពការណ៍រួម និងសភាព-ការណ៍ពាក់ព័ន្ធនឹងវិស័យអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៅខេត្តបន្ទាយមានជ័យ និងខេត្តប៉ៃលិន

-អញ្ជើញចុះបេសកកម្មដើម្បីឈ្វេងយល់អំពីការអនុវត្តសិទ្ធិមនុស្ស និងដោះស្រាយពាក្យបណ្តឹងរបស់អាជ្ញាធរថ្នាក់ក្រោមជាតិ នៅខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ

-អញ្ជើញចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មានជាមួយថ្នាក់ដឹកនាំស្រុក និងអាជ្ញាធរមូលដ្ឋាន ភូមិភាគ២ ក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងខេត្តកំពង់ចាម

-អញ្ជើញចូលរួមក្នុងពិធីសំណេះសំណាល និងចុះសិក្សាឈ្វេងយល់អំពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តសៀមរាប ។

**២.២. មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៨ករណី ផ្ញើកំណត់បង្ហាញពាក្យបណ្តឹងចំនួន០៩ករណី ព្រមទាំងកំពុងពិនិត្យសិក្សាចំនួន០៨ករណី និងធ្វើលិខិតរំលឹកជំរុញការដោះស្រាយពាក្យបណ្តឹងចំនួន០១ករណី ទទួលឯកសារពាក្យបណ្តឹងពីក្រសួង ស្ថាប័ន ដែលផ្ញើជូនមកព្រឹទ្ធសភាជ្រាបចំនួន០៩ករណី

-អញ្ជើញចូលរួមកិច្ចប្រជុំស្តីពី លទ្ធផលវិជ្ជមាននៃការចូលរួមមហាសន្និបាតសភាប្រើប្រាស់ភាសាបារាំង (APF) លើកទី៤៤ របស់គណៈប្រតិភូក្រុមសភាជាតិកម្ពុជា(APF)

-អញ្ជើញចូលរួមប្រជុំក្រុមមិត្តភាពព្រឹទ្ធសភាជាមួយសភាសាធារណរដ្ឋប្រជាធិប-តេយ្យប្រជាមានិតឡាវ ដើម្បីផ្សព្វផ្សាយសេចក្តីសម្រេចចាត់តាំងក្រុមមិត្តភាពព្រឹទ្ធសភាជាមួយសភាសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

-អញ្ជើញចូលរួមវេទិកាអន្តរសាសនាថ្នាក់ជាតិដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សលើកទី២

-អញ្ជើញចូលរួមប្រជុំ ដើម្បីពិភាក្សាអំពីប្រតិបត្តិការថវិការបស់គណៈកម្មការជំនាញ និងក្រុមនានារបស់ព្រឹទ្ធសភា និងរក្សាបាននូវសុខដុមនីយកម្មក្នុងប្រតិបត្តិការហិរញ្ញវត្ថុ

-អញ្ជើញចូលរួមកិច្ចប្រជុំដើម្បីផ្សព្វផ្សាយផែនការការងារគ្រប់គ្រងបរិស្ថាន និងធនធានធម្មជាតិរបស់ក្រសួងបរិស្ថាន

-អញ្ជើញចូលរួមជាអធិបតី និងជាវាគ្មិនក្នុងសិក្ខាសាលាស្តីពី ការអភិវឌ្ឍសហគមន៍ក្រីក្រនៅតំបន់ទីប្រជុំជន

-អញ្ជើញចូលរួមសិក្ខាសាលាផ្សព្វផ្សាយច្បាប់ស្តីពី លក្ខន្តិកៈមន្ត្រីរាជការស៊ីវិលសភាចរស្តីពី ការកែសម្រួលនីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ អនុក្រឹត្យស្តីពី ការសុំច្បាប់ និងការអនុញ្ញាតច្បាប់ឈប់គ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យស្តីពី ការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

-អញ្ជើញចូលរួមប្រជុំជាមួយក្រុមសមាជិកាព្រឹទ្ធសភាស្តីពី ការពិភាក្សាឆ្លងកម្មវិធីចុះជួបសមាជិកាក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងចន្លោះសម័យប្រជុំរបស់ព្រឹទ្ធសភា

-អញ្ជើញចូលរួមកិច្ចប្រជុំ ដើម្បីពិនិត្យពិភាក្សាលើស្ថានភាពនៃការអនុវត្តក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះទៅតាមបណ្តាខេត្ត ក្រុង រាជធានីភ្នំពេញចំនួន១៣៣លើក ដើម្បីជួបពិភាក្សាការងារ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ កងទ័ព សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យ និងព្យាបាលជំងឺជូនប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានាតាមដានការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព សិក្សាឈ្វេងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំងបានចូលរួមក្នុងពិធីផ្សេងៗ និងពិធីផ្សេងៗសរុបចំនួន៦៨លើក ។

**៣. កិច្ចសហប្រតិបត្តិការអន្តរជាតិ** :

-លោកជំទាវ **ទី បូរ៉ាស៊ី** អញ្ជើញចូលរួមវេទិកាស្ត្រីអាស៊ី-អឺរ៉ុបលើកទី២ នៅសហព័ន្ធរុស្ស៊ី

-ឯកឧត្តម **យ៉ង់ សែម** អញ្ជើញចូលរួមកិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប (ASEP) លើកទី១០ នៅទីក្រុងប្រ៊ុចសែល ប្រទេសប៊ែលហ្ស៊ិក និងចូលរួមពិធីអបអរសាទរខួប ៦០ឆ្នាំនៃទំនាក់ទំនងការទូតចិន-កម្ពុជា នៅសាធារណរដ្ឋប្រជាមានិតចិន

-ឯកឧត្តម **យ៉ង់ សែម** លោកជំទាវ **មាន សំអាន** ឯកឧត្តម **ឈិត គឹមយាត** ឯកឧត្តម **ប្រាក់ ចំរើន** ឯកឧត្តម **ខៀវ មុត** និងលោកជំទាវ **ឃួន ឃុនឌី** អញ្ជើញចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៣៩ នៅសាធារណរដ្ឋសិង្ហបុរី

-ឯកឧត្តម **ឈិត គឹមយាត** អញ្ជើញចូលរួមពិព័រណ៍ពាណិជ្ជកម្មអន្តរជាតិចិនភាគខាងលិចលើកទី១៧ នៅទីក្រុង Chengdu ខេត្ត Sichuan នៃសាធារណរដ្ឋប្រជាមានិតចិន

-ឯកឧត្តម **ឆាយ វណ្ណា** អញ្ជើញចូលរួមវេទិកាសភាពិភពលោកទី២ស្តីពី ការអភិវឌ្ឍប្រកបដោយចីរភាព ក្រោមប្រធានបទ ភាពជាដៃគូឆ្ពោះទៅរកថាមពលប្រកបដោយចីរភាពសម្រាប់យើងទាំងអស់គ្នា នៅទីក្រុងបាលី នៃសាធារណរដ្ឋឥណ្ឌូនេស៊ី

-ឯកឧត្តម **ឡៅ មុត** និងឯកឧត្តម **ឆាយ វណ្ណា** អញ្ជើញចូលរួមវេទិកា Eval Colombo 2018 ក្រោមប្រធានបទ សភាប្រកបដោយការទទួលខុសត្រូវ និងការជំរុញលើកកម្ពស់ការវាយតម្លៃនៅក្នុងយុគសម័យរបៀបវារៈ ២០៣០ នៅប្រទេសស្រីលង្កា

-ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** អញ្ជើញទទួលជួបពិភាក្សាការងារជាមួយក្រុមអ្នកវិនិយោគទុនមកពីប្រទេសជប៉ុន ដឹកនាំដោយលោក Yamamoto Japan និងបានចុះពិនិត្យមើលការចាប់ផ្តើមអនុវត្តន៍គម្រោងសាងសង់ទីលានប្រណាំងរថយន្ត និងបង្ហាត់បង្រៀនឱ្យចេះប្រើប្រាស់រថយន្តជាច្រើនប្រភេទ ព្រមទាំងទទួលជួបភ្ញៀវមកពីតៃវ៉ាន់ ដែលមានគម្រោងចង់វិនិយោគទុននៅប្រទេសកម្ពុជា ។/

ថ្ងៃអង្គារ ៧កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូន:

- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ